Business for Social Responsibility

111 Sutter Street
12th Floor
San Francisco
CA 94104 USA
T 415.984.3200
F 415.984.3201
www.bsr.org

០២ មិនា ២០០៧

ជូនចំពោះ: បណ្តាដៃគូនៅក្នុងកម្មវិធី *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ

ក្នុងនាមជាអ្នកចូលរួមយ៉ាងសកម្ម នៅក្នុងកម្មវិធី *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ យើងខ្ញុំសូមសំដែងនូវការព្រួយបារម្ភ ដោយបានលឺមតិនាពេលថ្មីៗនេះ ដែលបញ្ចេញដោយមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល ដែលបានចោទសួរលើសុចរឹតភាពរបស់ក្រុមពិនិត្យឃ្លាំមើលរបស់អង្គការពលកម្មអន្តរជាតិ និង ភាពអាចជឿជាក់បាននៃរបាយការណ៍រោងចក្រ របស់ពួកគេ ។

យើងខ្ញុំប្រកាន់ជំហចំពោះគំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ដោយការគោរពខ្ពស់បំផុត ហើយ មានជំនឿទុកចិត្តយ៉ាងខ្លាំងក្លា ចំពោះអព្យាក្រឹតភាព និង ឯករាជ្យភាពរបស់អង្គការពលកម្មអន្តរជាតិ ។ យើងខ្ញុំទទួលបានការអះអាងបញ្ជាក់ពីថ្នាក់ដឹកនាំរបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា*ថា ពួកគេចាត់ទុកឥរិយាបថប្រកបដោយគុណធម៌ថាមានសារៈសំខាន់បំផុត ចំពោះសវនកររបស់ពួកគេ បាននិងកំពុងពង្រឹងដំណើរការនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ពួកគេ ហើយ នៅតែមានការប្តេជ្ញាចិត្ត ដើម្បីសំរេចអោយបាននូវតម្លាភាពសាធារណៈយ៉ាងពេញលេញនៃយន្តការត្រួតពិនិត្យទាំងនេះ ។

យើងចាត់ទុកជោគជ័យនៃកម្មវិធី *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ថាជាផ្នែកមួយដែលមានសារៈសំខាន់បំផុតនៃភាពប្រកួតប្រជែងរបស់ឧស្សាហកម្មកាត់ដេររបស់កម្ពុជា ។ កត្តាមួយ ក្នុងចំណោមកត្តាគន្លឹះនានា ដែលធ្វើអោយកម្មវិធីនេះមានភាពអាចជឿជាក់បាន គឺការបន្តការប្តេជ្ញាចិត្តរបស់គ្រប់អ្នកដែលមានការពាក់ព័ន្ធចូលរួមទាំងអស់ ។ យើងនៅតែមានការប្តេជ្ញាចិត្តយ៉ាងខ្លាំក្លា ចំពោះកម្មវិធីនេះ ហើយ រំពឹងយ៉ាងពេញលេញថាការចូលរួមពីគ្រប់រោងចក្រដៃគូនៅក្នុងប្រទេសកម្ពុជារបស់យើងទាំងអស់ នឹងនៅតែបន្តយ៉ាងសកម្មទៅមុខទៀត ។

ពី

អាឌីដាស - សាឡូម៉ុន (adidas - Salomon)

សហគ្រាសឌីសនី (Disney Enterprises, Inc.)

ហ្គេប (Gap Inc.)

អេច អេន អឹម (H&M)

ក្រុមវាយនភ័ណ្ឌចូន (Jones Apparel Group)

លីវ៉ាយ (Levi Strauss & Co.)

ណៃគី (Nike)

ឌឹ ឆៀលឌ្រិនស៍ផ្លេស (The Children's Place)

វ៉លម៉ាត (Wal-Mart Stores, Inc.)

អាជីវកម្មសំរាប់ការទទួលខុសត្រូវសង្គម (Business for Social Responsibility – BSR) ចេញផ្សាយសេចក្តីថ្លែងនេះ ជំនួសមុខអោយហត្ថលេខីខាងលើនេះ។ BSR គឺជាអង្គការសកលមួយ ដែលជួយក្រុមហ៊ុនជាសមាជិក អោយសំរេចបានជោគជ័យ តាមបែបមួយដែលគោរពដល់តំលៃគុណធមិ មនុស្ស សហគមន៍ និង បរិស្ថាន។ ទស្សនៈ ដែលបានបញ្ចេញនៅក្នុងសេចក្តីថ្លែងខាងលើ គឺជាទស្សនៈរបស់ក្រុមហ៊ុននីមួយៗ ហើយ មិនមែនជាទស្សនៈរបស់ BSR ក្នុងនាមជាអង្គការមួយនោះទេ។